# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាជាមួយអដ្ឋិធាតុរបស់សន្ត លូវីស និងសន្តី ហ្សឺលី ម៉ាតាំង
# ចំការទៀង ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩
# ប្ដីប្រពន្ធដែលបង្កើតគ្រួសារធំនើប

**អត្ថបទទី១៖ ថេស្សាឡូនិក ទី១ ២,១-៨**

សេចក្តីដែលយើងទូន្មានមិនមែនមកពីការភាន់ច្រឡំ មកពីគោលបំណងមិនល្អ ឬកលល្បិចណាឡើយ។ ១ថស ២,៣

**ដំណឹងល្អ៖ ម៉ាថាយ ២៣,២៣-២៦**

ពួកបណ្ឌិតខាងវិន័យ និងពួកផារីស៊ីដ៏មានពុតអើយ! អ្នករាល់គ្នាត្រូវវេទនាជាពុំខាន ព្រោះអ្នករាល់គ្នាសម្អាតពែង និងចាន តែខាងក្រៅប៉ុណ្ណោះ ប៉ុន្តែ ផ្ទៃកខាងក្នុងពោរពេញទៅដោយផលដែលកើតមកពីការកេងប្រវ័ញ្ច និងការលោភលន់។ មថ ២៣,២៥

បងប្អូនជាទីស្រឡាញ់!

យើងជាមហាគ្រួសារតែមួយ ដែលរួមគ្នាជួបគ្នាជាមួយសន្ត លូវីស និងសន្តី ហ្សឺលី ម៉ាតាំង ជាប្តីប្រពន្ធដ៏វិសុទ្ធដែលព្រះសហគមន៍ទទួលស្គាល់ថា ប្ដីប្រពន្ធទាំងពីរនាក់នេះជាគ្រួសារគំរូយ៉ាងអស្ចារ្យសម្រាប់គ្រួសារទាំងអស់នៅក្នុងពិភពលោក នៅក្នុងព្រះសហគមន៍របស់យើង និងនៅក្នុងសង្គមរបស់យើងដែរ។ យើងមានអំណរសប្បាយដោយបានទទួលអដ្ឋិធាតុ នៅក្នុងកោដ្ឋនេះយើងមានឆ្អឹងរបស់ពីរនាក់ដែលជាប្តីប្រពន្ធ មានកូនសរុបទាំងអស់៩នាក់ក្នុងនោះមាន៤នាក់ដែលបានទទួលមរណភាព ម្នាក់ពេលនៅក្នុងផ្ទៃពោះ ២នាក់ពេលនៅក្មេងខ្ចី ម្នាក់ពេលអាយុ៥ឆ្នាំ នៅសល់កូនស្រី៥នាក់ទៀតដែលប្តីប្រពន្ធនេះបានចិញ្ចឹមអស់ពីសមត្ថភាព។ គេបានរស់នៅ១០០ឆ្នាំមុន ពីរថ្ងៃមុនបានធ្វើដំណើរពីប្រទេសបារាំងមកប្រទេសកម្ពុជា ដើម្បីសួរសុខទុក្ខគ្រួសារទាំងអស់ ជាពិសេសគ្រួសារនៅក្នុងព្រះសហគមន៍កាតូលិកយើង។

នៅក្នុងព្រះសហគមន៍ចំការទៀង និងព្រះសហគមន៍ក្នុងខេត្តតាកែវទាំងមូល ថ្ងៃនេះយើងមានអំណរសប្បាយទទួលស្វាគមន៍ឪពុកម្តាយនិងប្តីប្រពន្ធដ៏វិសុទ្ធ ដែលណែនាំឲ្យយើងអាចភ្ញាក់ស្មារតីអំពីជីវិតរបស់យើងផ្ទាល់។ ប្រសិនបើយើងសួរខ្លួនឯង **តើជីវិតរបស់ខ្ញុំមានគោលដៅអ្វីខ្លះ? តើជីវិតរបស់ខ្ញុំចង់ទៅដល់ណា? តើជីវិតខ្ញុំត្រូវទៅផ្លូវណាដើម្បីឲ្យខ្ញុំរកឃើញសេចក្តីសុខ?** សម្រាប់យើងដែលជាគ្រីស្តបរិស័ទ គឺធ្វើយ៉ាងម៉េចទៅជាជនដ៏វិសុទ្ធ និងថ្ងៃនេះនៅពេលដែលយើងទទួលពីរនាក់ដែលជាប្តីប្រពន្ធដ៏វិសុទ្ធ មានន័យថាជាសន្តបុគ្គលណែនាំឲ្យយើងយល់ថាតាមពិតយើងអាចធ្វើបានដែរ មិនមែនទុកឲ្យបុព្វជិតបុព្វជិតាតែប៉ុណ្ណឹង។ នៅក្នុងពុទ្ធសាសនាអ្នកដែលអាចចូលក្នុងព្រះនិព្វានមានតែព្រះសង្ឃ ពុទ្ធបរិស័ទធម្មតាមិនអាចចូលបានទេ។ ប៉ុន្តែ នៅក្នុងគ្រីស្ត

សាសនាយើង គោលដៅរបស់យើងដែលធ្វើជាអ្នកវិសុទ្ធអាចធ្វើបាន នឹងថ្ងៃនេះដែលយើងទទួលសន្ត លូវីស និងសន្តី ហ្សេលី ជាឱកាសមួយដើម្បីនឹកឃើញប្តីប្រពន្ធដែលមានជីវិតធម្មតា ដែលជាសង្សារមុនរៀបការ ពេលរៀបការហើយបានទទួលស្វាគមន៍កូនៗយ៉ាងច្រើន។ ព្រះសហាគមន៍បានទទួលស្គាល់ថាគេជាសន្តសន្តី ជាអ្នកដ៏វិសុទ្ធយ៉ាងពេញលក្ខណៈ។

ហ្សេលី ធ្លាប់និយាយថា "**ខ្ញុំចង់ធ្វើជាសន្តីមួយ ប៉ុន្តែខ្ញុំមិនដឹងថាខ្ញុំត្រូវការចាប់ផ្តើមរបៀបណាដើម្បីទៅជាសន្តីដ៏ពេញលក្ខណក៏ប៉ុន្តែពីមួយថ្ងៃទៅមួយថ្ងៃខ្ញុំនឹកឃើញ ឱព្រះជាម្ចាស់អើយ ខ្ញុំចង់ធ្វើជាសន្តីមួយជួយខ្ញុំផង**"។ លូវីស ធ្លាប់និយាយថា "**នៅក្នុងជីវិតរបស់ខ្ញុំ ខ្ញុំមានគោលដៅតែមួយគត់ គឺស្រឡាញ់ព្រះជាម្ចាស់អស់ពីដួងចិត្តរបស់ខ្ញុំ**"។ សន្តី ហ្សេលី គាត់មានគោលបំណងទៅជាសន្តីមួយ ទៅជាអ្នកដ៏វិសុទ្ធម្នាក់ គាត់មានគោលបំណងនៅក្នុងដួងចិត្តរបស់គាត់ ប៉ុន្តែគាត់មិនដឹងថាធ្វើយ៉ាងឲ្យបានជោគជ័យ។ ដូច្នេះ ដើម្បីទៅមុខបានគាត់ចេះតែនិយាយទៅព្រះជាម្ចាស់ ឱព្រះជាម្ចាស់អើយ សូមជួយខ្ញុំផងឲ្យខ្ញុំទៅជាសន្តីដ៏តូចតាចមួយរូប។ លូវីស គាត់ដូចជាបានពន្យល់យើងយ៉ាងច្បាស់ ជីវិតដ៏វិសុទ្ធ គឺស្រឡាញ់ព្រះជាម្ចាស់អស់ពីដួងចិត្តនេះជាជីវិតរបស់យើង។ ជីវិតរបស់ជាគ្រីស្តបរិស័ទគឺហ្នឹង ធ្វើយ៉ាងម៉េចឲ្យយើងស្រឡាញ់ព្រះជាម្ចាស់អស់ពីដួងចិត្ត ធ្វើយ៉ាងម៉េចដើម្បីណែនាំឲ្យព្រះជាម្ចាស់ស្រឡាញ់យើង អស់ព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គ និងធ្វើយ៉ាងម៉េចដើម្បីស្រឡាញ់បងប្អូនឯទៀតៗអស់ពីកម្លាំងកាយកម្លាំងចិត្ត។

ដូច្នេះ ធ្វើជាសន្តសន្តី ធ្វើជាអ្នកដ៏វិសុទ្ធ នេះមិនមែនសម្រាប់តែអ្នកដែលបួសអស់មួយជីវិត ហ្សេលី ពីដើមគាត់ចង់ធ្វើជាបងស្រី ប៉ុន្តែពេលគាត់ចូលនៅក្នុងក្រុមគ្រួសារធ្វើជាដូនជី ប្រធានគ្រួសារនោះគាត់ថា សុំទោសកូនអើយ ធ្វើដូនជីមិនបាន ដូច្នេះសុំចូលនៅក្នុងជីវិតធម្មតាវិញ។ លូវីស ក៏ដូចគ្នាដែរគាត់ចង់ធ្វើជាបូជាចារ្យ គាត់ចូលនៅក្នុងក្រុមទេវវិទ្យាល័យដើម្បីធ្វើជាបូជាចារ្យ ប៉ុន្តែគេឃើញថាគាត់មិនពូកែដើម្បីរៀនទេវវិទ្យា ដូច្នេះគេថា សុំទោសកូនអើយ កូនធ្វើបូជាចារ្យមិនបានទេ។ ទាំងពីរនាក់បានជួបគ្នានៅលើស្ពានមួយ គេបានមើលមុខគ្នាលើកដំបូងគេបានធ្លាក់នៅក្នុងរឿងស្នេហា ដូច្នេះលូវីសដែលចង់ធ្វើជាបូជាចារ្យចេញពីទេវៈ ហ្សេលីដែលចង់ធ្វើជាបងស្រីចេញពីក្រុមបងស្រី គេរៀបការបីខែក្រោយមក។ គេធ្វើតាមគម្រោងការណ៍របស់ព្រះជាម្ចាស់ គឺណែនាំឲ្យមានកូនច្រើន ដូច្នេះគេខិតខំបន្តជីវិតដែលគេបានទទួលពីព្រះជាម្ចាស់ គឺណែនាំឲ្យមានកូនដែលគេស្រឡាញ់។ នៅពេលយើងឃើញទាំងពីរនាក់ យើងនឹកឃើញដល់អត្ថបទទី១ "**អ្វីដែលសំខាន់នៅក្នុងធម្មវិន័យ គឺមានសេចក្តីសុចរិត មេត្តាករុណាធម៌ និងជំនឿស្មោះត្រង់**" ជាអ្វីដែលគេបានអនុវត្តនៅក្នុងជីវិត យុត្តិធម៌នៅក្នុងជីវិត មេត្តាករុណារវាងគ្នានិងគ្នាជាប្តីប្រពន្ធ ជូន

ពរកូនរបស់គេ ខិតខំស្រឡាញ់កូនរបស់ពួកគេអស់ពីដួងចិត្តអស់ពីសេចក្តីស្រឡាញ់ លះបង់ចោលដើម្បីកូនគេ និងមានចិត្តស្មោះចំពោះគ្នាទៅវិញទៅមកនិងចំពោះព្រះជាម្ចាស់។

បច្ចុប្បន្ននេះ សង្គមជូនកាលណែនាំឲ្យយើងចង់ផ្លាស់ប្តូរយ៉ាងច្រើនណាស់ យើងគិតថា យើងនៅជាមួយស្រីមួយរយៈហើយយើងដូរទៀត យើងនៅជាមួយប្រុសមួយរយៈហើយយើងដូរទៀត។ នេះជារបៀបនៃសង្គមយើងសព្វថ្ងៃ យើងត្រូវគ្នាមួយខែពីរខែ យើងត្រូវគ្នាមួយឆ្នាំពីរឆ្នាំ និងក្រោយមកយើងថាល្មមហើយទៅយកអ្វីផ្សេង សង្គមរបស់យើងណែនាំឲ្យយើងដូច្នេះ។ សង្គមរបស់យើង ណែនាំឲ្យយើងប្រែប្រួលច្រើនណាស់ ពេលយើងប្រើហើយយើងចោល ពេលយើងនៅជាមួយគ្នាមួយរយៈយើងចោល។ ថ្ងៃនេះ ព្រះជាម្ចាស់ណែនាំឲ្យយើងនឹកឃើញមានតែភក្តីភាព ដែលណែនាំឲ្យយើងទៅមុខនៅក្នុងអនាគត ប៉ុន្តែភក្តីភាពណែនាំឲ្យយើងតស៊ូដើម្បីទៅមុខទៀត នៅពេលយើងធ្លាក់ នៅយើងមានបញ្ហាណាមួយ យើងតស៊ូថែមទៀតដើម្បីទៅមុខទៀត។ ឆ្នាំនេះ ជាខួប៥០ឆ្នាំនៃអាពាហ៍ពិពាហ៍របស់ឪពុកម្តាយខ្ញុំ អស្ចារ្យអាទិត្យនេះឪពុកម្តាយខ្ញុំនៅទីក្រុងលីហ្សៀ ដែលពីរនាក់នេះនៅ លូវីស និងហ្សឺលី មកប្រទេសកម្ពុជា ឪពុកម្តាយខ្ញុំនៅលីហ្សៀ ដែលកំពុងអធិដ្ឋានឲ្យកម្មវិធីយើងជោគជ័យ។ ជីវិតរបស់យើងគឺជាជីវិតធម្មតា ប៉ុន្តែកុំឲ្យយើងយល់ច្រឡំថា ទៅជាមនុស្សវិសុទ្ធមិនមែនយើងត្រូវជាមនុស្សជាប់លេខ១ ទៅជាមនុស្សអស្ចារ្យមិនមែនរឿងនឹងទេ។ ជីវិតដ៏វិសុទ្ធ មានន័យថាយើងរស់នៅជាមួយព្រះជាម្ចាស់ ជូនកាលយើងជាប់នឹងអំពើបាប ជូនកាលយើងធ្លាក់ទឹកចិត្ត ជូនកាលប្តីប្រពន្ធយើងឈ្លោះគ្នានិងមានរឿងអន់ចិត្តគ្នា ជូនប្តីប្រពន្ធជាមួយកូនយើងមានរឿងឈ្លោះគ្នា ក៏ប៉ុន្តែយើងទៅមុខតទៅទៀតដោយដឹងថាព្រះជាម្ចាស់លើកលែងទោសឲ្យយើង ដោយសារព្រះជាម្ចាស់មានព្រះហឫទ័យមេត្តាករុណាជានិច្ច និងណែនាំឲ្យយើងខិតខំលើកលែងទោសឲ្យគ្នាទៅវិញទៅមក ដូចហ្សឺលី និងលូវីស បានធ្វើ។

លូវីស គាត់ចូលចិត្តអធិដ្ឋាន ពីមួយថ្ងៃទៅមួយថ្ងៃអត់ដែលភ្លេចថ្ងៃណាមួយ ដែលគាត់យកមួយម៉ោងដើម្បីអធិដ្ឋាន។ ជាពិសេស គាត់ចូលចិត្តយកព្រះបន្ទូលមួយ ឬឃ្លាមួយដើម្បីបំភ្លឺជីវិតរបស់គាត់ពីមួយថ្ងៃទៅមួយថ្ងៃ។ សន្តីតេរេសា (កូនស្រីគាត់) ធ្លាប់និយាយថា "**ខ្ញុំឮឪពុកខ្ញុំប៉ុន្មានដងអធិដ្ឋានខ្សិបៗនៅក្នុងបបូរមាត់របស់គាត់ ឱព្រះជាម្ចាស់អើយ សូមថែមជំនឿឲ្យខ្ញុំផង**"។ ដូច្នេះ ទោះបីគាត់ធ្វើការ ទោះបីគាត់មើលកូន ទោះបីគាត់ថែរក្សាប្រពន្ធ ទោះបីគាត់ជួយការងារផ្ទះ ទោះបីគាត់នៅជាមួយក្រុមគ្រួសារ ទោះបីគាត់នៅជាមួយមិត្តភក្តិរបស់គាត់ គាត់នឹកឃើញព្រះជាម្ចាស់ជានិច្ច ឱព្រះជាម្ចាស់អើយសូមជួយថែមជំនឿឲ្យខ្ញុំផង។ ហ្សឺលី គាត់ចូលចិត្តបម្រើការងារផ្ទះគាត់ធ្វើការយ៉ាងច្រើន ពីមួយថ្ងៃទៅមួយថ្ងៃគាត់អត់ដែលមានពេលដើម្បីសម្រាក រហូត

ដល់គាត់កើតជម្ងឺមហារីកនិងគាត់ស្លាប់ នៅពេលនោះសន្តីតេរេសាអាយុតែ៩ឆ្នាំ។ ប៉ុន្តែគាត់និយាយថា "**ខ្ញុំពោរពេញដោយអំណរសប្បាយ នៅពេលខ្ញុំយល់ថាពេញមួយថ្ងៃនេះខ្ញុំបានជួយបម្រើទាំងប្តីខ្ញុំ ទាំងកូនខ្ញុំ ទាំងបងប្អូនខ្ញុំ នៅពេលខ្ញុំឃើញខ្ញុំជាអ្នកបម្រើនិងខ្ញុំបំពេញតួនាទីខ្ញុំជាអ្នកបម្រើ ខ្ញុំពោរពេញដោយអំណរសប្បាយ**"។ នេះជាប្តីប្រពន្ធមួយយ៉ាងពិសេស ដែលបានធ្វើដំណើរជាមួយគ្នាជានិច្ច និងហ្សេលី គាត់កោតសរសើរលូវីសជានិច្ច រហូតដល់គាត់និយាយថា "**ប៉ាវាអស្ចារ្យណាស់ ប៉ាវាអត់ដែលនិយាយដើមគេសោះ គាត់ចេះតែលើកទឹកចិត្ត គាត់ចេះតែលះបង់ គាត់ចេះតែតស៊ូ**"។ នៅពេល លូវីស គាត់និយាយពីប្រពន្ធប្រាប់កូនគាត់ថា "**សូមមើលម៉ែ ជាម៉ែវិសុទ្ធពិតមែន**"។ នេះជារបៀបដែល លូវីស និងហ្សេលី និយាយអំពីគ្នាទៅវិញទៅមក ដោយទទួលស្គាល់ថាប្តីជាប្តីមួយដែលយកចិត្តទុកដាក់ ដែលស្រឡាញ់ជានិច្ច និងប្រពន្ធជាប្រពន្ធដ៏វិសុទ្ធ។

បងប្អូនជាទីស្រឡាញ់!

បងប្អូនដែលមានគ្រួសារហើយ បងប្អូនដែលមិនទាន់មានគ្រួសារ ដែលជាគ្រួសារដែលជួបទុក្ខលំបាកក៏ដោយ ដែលជាគ្រួសារដែលពោរពេញដោយក្តីសុខក៏ដោយ ថ្ងៃនេះជាឱកាសមួយដើម្បីនឹកឃើញគោលបំណងរបស់យើង គឺមានជីវិតដ៏វិសុទ្ធ។ គោលបំណងរបស់យើង គឺធ្វើដំណើរជាមួយគ្នាដើម្បីបង្កើតយុត្តិធម៌នៅក្នុងសង្គម នៅក្នុងគ្រួសារយើង។ គោលបំណងរបស់យើង គឺរស់នៅក្នុងធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ជានិច្ច ដោយថែរក្សាភាពស្មោះត្រង់រវាងគ្នានិងគ្នា ជាមួយប្តីនិងប្រពន្ធ ជាមួយកូន ជាមួយសង្គម ជាមួយព្រះសហគមន៍ ដើម្បីឲ្យគ្រួសារនីមួយៗរបស់យើង ទៅជាព្រះសហគមន៍ដ៏តូចមួយដែលណែនាំឲ្យពិភពរបស់យើង ទៅជាពិភពថ្មី។ យើងដឹងថា នៅពេលគ្រួសាររស់នៅប្រកបដោយយុត្តិធម៌ ប្រកបដោយធម៌មេត្តាករុណា ប្រកបដោយភាពស្មោះត្រង់ ណែនាំឲ្យសង្គមរបស់យើងទៅជាសង្គមប្រែថ្មី ដើម្បីឲ្យយើងទាំងអស់គ្នារកឃើញផ្លូវនៃសុភមង្គល គឺយកចិត្តទុកដាក់ធ្វើជាមនុស្សដ៏វិសុទ្ធ។

ឱព្រះអង្គម្ចាស់អើយ! យើងអធិដ្ឋានដើម្បីឲ្យគ្រួសាររបស់យើង ព្រះសហគមន៍របស់យើង តាមរយៈសន្ត លូវី តាមរយៈសន្តី ហ្សេលី និងតាមរយៈសន្តី តេរេសា នៃព្រះកុមារយេស៊ូដែលជាកូនរបស់គាត់ អាចរស់នៅក្នុងបច្ចុប្បន្ននេះ នៅក្នុងពិភពលោកនេះ ប្រកបដោយសេចក្តីសុខដើម្បីណែនាំឲ្យមនុស្សជាច្រើនរកឃើញជីវិត ជីវិតដែលមកពីព្រះជាម្ចាស់ សេចក្តីស្រឡាញ់ដែលមកពីព្រះជាម្ចាស់។ អាម៉ែន៕